# <u>សហព័ន្ធអន្តរជាតិកីឡាប៉េតង់ និង</u> JEU PROVENCAL

# <u>បទប្បញ្ញត្តិនៃការរៀបចំការប្រកួតជើងឯកពិភពលោក</u>
# ជំពូកទី ១ - ច្បាប់ទូទៅ

**<u>មាត្រាទី ១៖</u>**

FIPJPគឺជាសហព័ន្ធកីឡាប៉េតង់អន្តរជាតិតែមួយគត់ដែលបានទទួលស្គាល់ដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ ដែលស្ថិតក្រោមទម្រង់នៃប្រភេទកីឡាប៊ូល(CMSB)។ ហើយក៏ជាសហព័ន្ធតែមួយដែលមានសិទ្ធិអនុញ្ញាត្តិឲ្យរៀបចំការប្រកួតរើសជើងឯកពិភពលោកនិងផ្តល់នូវពានរង្វាន់ដល់អ្នកឈ្នះ។

**<u>មាត្រាទី ២៖</u>**

ស្ថាប័ន FIPJPរៀបចំការប្រកួតជ្រើសរើសជើងឯកពិភពលោកទៅតាមលំដាប់លំដោយនៃឆ្នាំដូចខាងក្រោម៖

- ជើងឯកពិភពលោកផ្នែកបុរស ត្រូវប្រព្រឹត្តនៅក្នុងឆ្នាំ «គូ»
- ជើងឯកពិភពលោកផ្នែកយុវជន (អាយុ ១៧ឆ្នាំក្នុងឆ្នាំប្រកួត ឬក្មេងជាងនេះ) ដែលប្រព្រឹត្តនៅក្នុងឆ្នាំ «សេស»
- ជើងឯកពិភពលោកផ្នែកស្រ្តី ត្រូវប្រព្រឹត្តនៅក្នុងឆ្នាំ «សេស»

ដែលជាទូទៅ ត្រូវមានការសហប្រតិបត្តិការរវាង FIPJP នឹងសហព័ន្ធជាតិឬសម្ព័ន្ធកីឡាដែលជាម្ចាស់ផ្ទះ។ យ៉ាងណាមិញ FIPJP ត្រូវតែរ៉ាប់រងទាំងស្រុងលើការរៀបចំដំណើរការ និងលទ្ធផលនៃការប្រកួតទាំងមូល។

ទន្ទឹមនឹងការប្រកួតនីមួយៗខាងលើបើសិនជាមានការជ្រើសរើសជើងឯកពិភពលោកខាងវាយស៊ីបត្រូវតែធ្វើស្របពេលជាមួយគ្នា។ រាល់ប្រកួតជើងឯកពិភពលោកត្រូវរៀបចំឲ្យស្របទៅតាមស្តង់ដា និងក្របខណ្ឌដែលបានចែងស្រេចស្រាប់។

**<u>មាត្រាទី ៣៖</u>**

ស្ថាប័នរៀបចំការប្រកួតត្រូវមានចាត់ជាយុទ្ធសាស្រ្តចំបងៗក្នុងការត្រៀមខ្លួនសម្រាប់រៀបចំការប្រកួតដូចជាឯកសារកម្មវិធីលម្អិត (សូមពិនិត្យមើលពត៌មានបន្ថែមនៅក្នុងប្រការ ៣ នៃបទបញ្ជាផ្ទៃក្នុង ដោយមានចំណងជើងថា «ប្រធាន»)ជូនទៅប្រធានFIPJPឬគណៈប្រតិភូដែលចុះទៅតម្រួតទីកន្លែងប្រកួត។

**<u>មាត្រាទី ៤៖</u>**

ប្រតិទិននៃការប្រកួតរើសជើងឯកពិភពលោកត្រូវដាក់ឲ្យអង្គសមាជនៃមហាសន្និបាតប្រចាំឆ្នាំរបស់FIPJPតាមការស៊ុំនិងយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ FIPJP ដើម្បីសម្រេច។

**<u>មាត្រាទី ៥៖</u>**

តារាងនៃពេលវេលាប្រកួតជើងឯកពិភពលោកត្រូវសម្រេចដោយគណៈកម្មការរៀបចំការប្រកួតដោយមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិFIPJP។ ដោយឡែកមានការផ្តល់អទិ្ធភាពដល់ការប្រកួតផ្នែកបុរស។ ពេលវេលានៃការប្រកួតទាំងគ្រប់វិញ្ញាសារមានការស្នើពីគណៈកម្មាធិការប្រតិបត្តិFIPJPឲ្យរៀបចំដូចតទៅនេះ ៖

- ការប្រកួតរើសជើងឯកពិភពលោកផ្នែកបុរស គួរប្រព្រឹត្តឡើងនៅខែកញ្ញា។
- ការប្រកួតរើសជើងឯកពិភពលោកផ្នែកនារីធ្វើនៅខែកក្កដា
- ការប្រកួតរើសជើងឯកពិភពលោកយុវជនវ័យក្មេងធ្វើនៅរដូវវិស្សមកាលរបស់សិស្ស។

**មាត្រា ទី៦៖**

ការប្រកួតត្រូវធ្វើឡើងលើសពី៣ថ្ងៃគឺពីថ្ងៃសុក្រដល់ថ្ងៃអាទិត្យ។
ទោះជាយ៉ាងណាក៏ដោយតារាងពេលវេលានៃការប្រកួតអាចកែប្រែបានបើមានការអនុញ្ញាតពីគណកម្មាការប្រតិបត្តរបស់FIPJP ដោយមានការយកយល់ពីប្រពៃណីនៃប្រទេសនិមួយៗ។
ដើម្បីកុំឲ្យធាតុអាកាសរំខានការប្រកួត, គណៈកម្មាការនៃការរៀបចំការប្រកួតត្រូវតែធ្វើការប្រកួតក្នុងទីលានដែលមានដំបូល។
ក្នុងពេលប្រកួតរើសជើងឯកពិភពលោកនេះមិនត្រូវឲ្យមានការប្រកួតអ្វីទៀតក្រៅពីការប្រកួតនូវពានរង្វាន់ជាតិ(coupe de nation)

**ជំពូកទី២ (ការចូលរួបរួម)**

**មាត្រាទី៧៖**

សហព័ន្ធណាដែលបានបង់វិភាគទានជាសមាជិកដល់FIPJPមានសិទ្ធិចុះឈ្មោះកីឡាករ១ក្រុមឲ្យចូលប្រកួតជំរើសជើងឯកពិភពលោកឬចូលក្នុងចំណាប់ថ្នាក់បំរុងរាប់ចូលទាំងសហព័ន្ធដែលជាម្ចាស់មេដាយមាសឬសហពន្ធ័ដែលធ្វើជាម្ចាស់ផ្ទះ។សហពន្ធ័ដែលមានការទទួលស្គាល់ជាបណ្តោះអាសន្នពីគណៈកម្មាធិការប្រតិបត្តិក៏អាចមានសិទ្ធិចុះឈ្មោះក្រុមរបស់ខ្លួនឲ្យចូលរួមបានដែរ។ការចុះឈ្មោះចូលរួមនេះត្រូវធ្វើតាមការកំណត់ពេលវេលាដែលចែងឲ្យ។ព្រមទាំងឲ្យដំណឹងនេះដល់គណៈកម្មាធិការប្រតិបត្តិមុនពេលបើកប្រជុំមហាសន្និបាតប្រចាំឆ្នាំរបស់គណៈកម្មាធិការប្រតិបត្តិនេះ។
បើសិនជាប្រទេសដែលចុះឈ្មោះចូលរួមប្រកួតមិនមានចំនួនគំរិតខ្ពស់, សហព័ន្ធដែលជាម្ចាស់ផ្ទះឬសហព័ន្ធដែលជាម្ចាស់មេដាយមាសអាចមានសិទ្ធិបន្ថែម១ក្រុមទៀតបើសិនជាមានបំណង។
ការផ្គត់ផ្គង់ក្នុងវិស័យហិរញ្ញដល់ប្រតិភូដែលចូលរួមក្នុងការប្រកួតបានចុះក្នុងសៀវភៅផ្គត់ផ្គង់(cahier de charge)។
ចំនួននៃក្រុមដែលចុះឈ្មោះប្រកួតក្នុងវិញ្ញាសារ ៣ ទល់ ៣បានកំរិតត្រឹមតែ៤៨ក្រុម(ប្រទេស១បាន១ក្រុម)។ចំនួនក្រុមដែលឲ្យចូលរួបរួមប្រកួតត្រូវត្រូវជ្រើសរើសតាមការប្រកួតជម្រុះនៃទ្វីបនិមួយៗ។ ចំនួនក្រុមដែលអនុញ្ញាតតាមទ្វីបនិមួយៗត្រូវកំរិតដោយគណៈកម្មាធិការប្រតិបត្តរបស់សហព័ន្ធអន្តរជាតិ១ឆ្នាំមុនពេលប្រកួត។ វិធានការនេះនឹងប្រព្រឹត្តទៅដូចគ្នានូវវិញ្ញាសារដ៏ទៃទៀតបើសិនជាចំនួនក្រុមប្រកួតលើសពីចំនួន៤៨ក្រុមឬតាមការសម្រាច់របស់មហាសន្និបាត។
សហព័ន្ធត្រូវតែផ្ញើនូវកិច្ចព្រមព្រៀងនៃការចូលរួបរួមប្រកួតដល់គណៈកម្មាធិការប្រតិបត្តិនៃសហព័ន្ធអន្តរជាតិនិងគណៈកម្មាការរៀបចំការប្រកួតរបស់ម្ចាស់ផ្ទះឲ្យទាន់ពេលវេលាដែលបានកំណត់ឲ្យ។

**<u>មាត្រាទី៨៖</u>**

ក្រុមដែលចូលប្រកួតក្នុងវិញ្ញាសារ៣ទល់និង៣, អាចមានគ្នា៤នាក់ប្រុសឬស្រីហើយអាចដូរបានតែម្តងក្នុង១ប្រកួតហើយត្រូវធ្វើក្នុងចន្លោះ២សេរ៉ា។

**<u>មាត្រាទី៩៖</u>**

ក្រុមប្រកួតនិងឈ្មោះរបស់គាត់ត្រូវបញ្ជូនឲ្យគណៈកម្មាការរៀបចំនិងគណៈកម្មាធិការប្រតិបត្តFIPJPបានមុន២ខែនៃការចាប់ផ្តើមប្រកួត។ទោះជាយ៉ាងណាក៏ដោយសមាសភាពនៃអ្នកប្រកួតទាំងអស់ឬភាគខ្លះអាចប្តូរបានក្នុងពេលចាប់ឆ្នោតប្រកួត។

**<u>មាត្រាទី ១០៖</u>**

ក្រុមដែលចូលរួមប្រកួតត្រូវមានសញ្ជាតិរបស់ប្រទេសដែលក្រុមខ្លួនតំណាងឲ្យ។ ប៉ុន្តែក៏នៅមានករណីលើកលែងខ្លះដែរ អាស្រ័យទៅតាមកិច្ចព្រមព្រៀងរវាងប្រទេសនិងប្រទេស ហើយមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិFIPJP ដោយមិនមានការជំទាស់ពីមហាសន្និបាតអន្តរជាតិ *(ក្នុងមួយក្រុមមានជនបរទេសត្រឹមតែម្នាក់អាចជាករណីដែលលើកលែងបាន)*។

ចំពោះជើងឯកពិភពលោកផ្នែកយុវជន(Junior)យុវជនដែលអាចជ្រើសរើសទៅប្រកួតជើងឯកពិភពលោកត្រូវមានកំណើតក្នុងប្រទេសដែលគាត់តំណាងឲ្យ,ជាសមាជិកនៃសហព័ន្ធរបស់ប្រទេសគាត់ហើយមិនដែលតំណាងឲ្យប្រទេសណាមួយទៀត។ ដូច្នេះចំពោះករណីនេះ ប្រធាននៃក្រុមត្រូវបញ្ជូនឯកសារតាមផ្លូវការបញ្ជាក់ពីទីកំណើតរបស់យុវជន។

កីឡាករឬកីឡាការនីជំរើសជាតិត្រូវតែជាសមាជិកនៃសហព័ន្ធរបស់ខ្លួនយ៉ាងតិច៦ខែ។
កាលបរិច្ឆេតនៃពេលវេលាអាចពន្យាទៅ៣ឆ្នាំចំពោះជនបរទេស។បើសិនជាជនបរទេសនោះបានប្រកួតឲ្យប្រទេសណាមួយផ្សេងទៀតដូចជាជំរើសជើងឯកពិភពលោក, ជំរើសជើងឯកទ្វីប, ពានរង្វាន់ទ្វីប, world gamesឬផ្សេងៗទៀត។
បើសិនជាយុវជននោះធ្លាប់តំណាងឲ្យប្រទេសផ្សេងក្នុង ការប្រកួតអន្តរជាតិ,ជើងឯកពិភពលោក,រើលខាប់(world cup) យុវជននោះត្រូវពន្យារដល់ ៥ ឆ្នាំ។

**<u>មាត្រាទី ១១៖</u>**

អាជ្ញាប័ណ្ណ(licence)ឬលិខិតបញ្ជាក់អ្នកកីឡានិងគណៈប្រតិភូត្រូវបង្ហាញដល់សមាជិកគណៈកម្មាធិការប្រតិបត្តិFIPJPមុនពេលចាប់ឆ្នោតប្រកួត។បើសិនជាមានការចាំបាច់អ្នកកីឡាត្រូវបង្ហាញនូវអ្វីមួយដែលបញ្ជាក់ថាខ្លួនជាសញ្ជាតិហ្នឹង។ចំពោះយុវជនវិញត្រូវតែបង្ហាញនូវអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនដើម្បីត្រួតមើលអាយុ។
សហព័ន្ធដែលជាប់ពាក់ព័ន្ធត្រូវទទួលបន្ទុករៀបចំឯកសារនិងលិខិតភស្តុតាងបើពុំដូច្នោះទេអាចនឹងមានវិធានការផ្លូវច្បាប់ទៅលើបុគ្គលដែលបានល្មើសនឹងបទបញ្ជា។

**<u>មាត្រាទី១២៖</u>**

ក្រុមប្រកួតនិមួយៗត្រូវមានមេកើយរបស់ខ្លួនដែលរៀបចំនិងរៀបសំរួលឲ្យអ្នកកីឡារបស់គាត់មានវិន័យត្រឹមត្រូវជាពិសេសត្រូវត្រួតមើលសម្លៀកបំពាក់របស់អ្នកកីឡាឲ្យស្លៀកពាក់បានត្រឹមត្រូវតាមក្បួនច្បាប់។
-មេកើយឬ(coach)ត្រូវមានម៉ែតសំរាប់វាស់វែងប៊ូលភ្ជាប់តាម ខ្លួនជានិច្ច។
-គាត់ត្រូវឲ្យដំណឹងជាបន្ទាន់ដល់ក្រុមរបស់គាត់បើមានការជូនព័ត៌មានពីលេខាធិការដ្ឋានប្រកួត។
-ប្រតិភូនិងគ្រូបង្វឹកត្រូវតែមានការរ៉ាប់រងនូវវិន័យរបស់អ្នកកីឡារបស់គាត់ហើយត្រូវតែគោរពនូវបទបញ្ជារបស់អ្នករៀបចំការប្រកួតបើមិនដូចឆ្នោះទេគេអាចបញ្ឈប់ឲ្យប្រកួតបាន។
ពេលគេហៅចូលប្រកួតប្រតិភូឬគ្រូបង្វឹកត្រូវនាំក្រុមរបស់គាត់ទៅដល់ទីលានដែលក្រុមរបស់គាត់ត្រូវប្រកួត។
ក្នុងពេលកំពុងប្រកួតគាត់មិនត្រូវរើខ្លួនឬលើកដៃធ្វើជាសញ្ញាពេលដែលកីឡាករឬកីឡាការនីកំពុងត្រៀមខ្លួនបោះគ្រាប់ប៊ូលរបស់ខ្លួនមិនតែប៉ុណ្ណោះហាមចូលទីលានដែលកំពុងប្រកួត។ ក៏ប៉ុន្តែគាត់អាចឆ្លើយតបនិងសំនួរឬឲ្យយោបល់ដល់ក្រុមរបស់គាត់បើសិនជាគ្មានការប៉ះពាល់ដល់ពេលវេលាកំណត់ឲ្យបោះប៊ូល។

**<u>មាត្រាទី ១៣៖</u>**

មេគណៈប្រតិភូត្រូវមានអាជ្ញាប័ណ្ណបង្ហាញពីសហព័ន្ធដែលខ្លួនជាអ្នកតំណាងឲ្យ។ទន្ទឹមនឹងនេះអ្នកតំណាង ឬគ្រូបង្វឹក អាចជាសមាជិកនៃសហព័ន្ធរបស់ប្រទេសមួយផ្សេងទៀតបាន។
ក្នុងករណីដែលប្រទេសមួយមានកីឡាករតិចជាងចំនួនដែលបានកំណត់អោយ*(៣នាក់)*ក្នុងពេលចាប់ឆ្នោតប្រកួត,ប្រទេសនោះនឹងមិនអនុញ្ញាតឲ្យចាប់ឆ្នោតឬចូលរួមប្រកួតបានទេ។

## ជំពូក ៣៖ ការរៀបចំផ្នែកបច្ចេកទេស

**<u>មាត្រាទី ១៤៖</u>**

កីឡាប៉េតង់ជើងឯកពិភពលោកត្រូវអនុវត្តឡើងឲ្យស្របតាមច្បាប់កីឡារបស់ FIPJP រាប់បញ្ចូលទាំងប្រការដែលទាក់ទិននឹងការប្រកួតកម្រិតពេលវេលា។

**<u>មាត្រាទី ១៥៖</u>**

ក្នុងមាត្រាទី៣នៃបទបញ្ជា,ប្រធានឬគណៈប្រតិភូរបស់សហព័ន្ធអន្តរជាតិ(FIPJP)ត្រូវរាយការណ៍ទៅឲ្យគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួនអំពីការរៀបចំការប្រកួតរបស់ម្ចាស់ផ្ទះ។

គណៈកម្មាធិការប្រតិបត្តិ(FIPJP)នឹងជ្រើសតាំងតំណាងរបស់ខ្លួនចំនួន៖

- ៣រូបសម្រាប់រៀបចំការប្រកួតផ្នែកបុរស
- ២រូប សម្រាប់ការប្រកួតផ្នែកយុវជន និងស្ត្រី។

អ្នកតំណាងទាំងនោះជាមួយនិងអ្នករៀបចំកម្មវិធីប្រកួតត្រូវតែសហការជាមួយគ្នាដើម្បីធានាឲ្យការប្រកួតនេះមានដំណើរការយ៉ាងរលូននិងយ៉ាងល្អប្រសើរ។

ការចាយវាយលើថ្លៃធ្វើដំណើររបស់អ្នកតំណាងនឹងត្រូវបានរ៉ាប់រងដោយ FIPJP រីឯការស្នាក់នៅអ្វីផ្សេងៗទៀតគឺជាបន្ទុករបស់គណៈកម្មាធិការរៀបចំកម្មវិធីម្ចាស់ផ្ទះដែលមានចែងក្នុង cahier de charge។

**<u>មាត្រាទី ១៦៖</u>**

គណៈកម្មាធិការប្រតិបត្តិ(FIPJP)តែងតាំងអាជ្ញាកណ្តាលអន្តរជាតិ២រូបសម្រាប់ការប្រកួតជើងឯកពិភពលោកផ្នែកបុរស និង ១រូបសម្រាប់ការប្រកួតផ្នែកយុវជននិងស្ត្រី។លើសពីនេះសហព័ន្ធម្ចាស់ផ្ទះត្រូវជ្រើសរើសអាជ្ញាកណ្តាលអន្តរជាតិយ៉ាងតិច១រូបដែលស្ថិតក្រោមការណែនាំរបស់អាជ្ញាកណ្តាលរបស់ FIPJP ។

FIPJPនឹងរ៉ាប់រងលើថ្លៃធ្វើដំណើររបស់អាជ្ញាកណ្តាលដែលខ្លួនបានចាត់តាំងនិងប្រាក់កម្រៃចាយវាយផ្សេងៗដែលត្រូវបើកជូនអាជ្ញាកណ្តាលដែលកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ(អាជ្ញាកណ្តាលទាំងអស់ត្រូវបានអត្រាស្មើគ្នាទោះបីជាអាជ្ញាកណ្តាលដែលជ្រើសតាំងដោយសហព័ន្ធម្ចាស់ផ្ទះ)។ចំពោះតម្លៃនៃការរស់និងស្នាក់នៅគឺជាបន្ទុករបស់ម្ចាស់ផ្ទះ។

**<u>មាត្រាទី ១៧៖</u>**

អ្នកកីឡាត្រូវមានឯកសណ្ឋានដូចគ្នាទាំងខោនិងអាវ   រីឯអាវក្រៅត្រូវមានសញ្ញាសហព័ន្ធដែលគាត់តំណាងអោយ។អ្នកកីឡាត្រូវបង្ហាញ ប័ណ្ណចេញចូល ដែលផ្តល់ឲ្យដោយគណៈកម្មាធិការរៀបចំកម្មវិធី។

អ្នកកីឡា,គណៈប្រតិភូនិងអាជ្ញាកណ្តាលមិនអាចជក់បារី,សេពគ្រឿងស្រវឹងឬប្រើប្រាស់ទូរស័ព្ទនៅក្នុងបរិវេណហាមឃាត់។

អាវក្រៅរបស់អ្នកកីឡាអាចដាក់សារ/រូបផ្សព្វផ្សាយពាណិជ្ជកម្មយ៉ាងច្រើនបានបីដែលមានសណ្ឋានដូចគ្នាសម្រាប់សមាជិកក្រុមទាំងអស់ ហើយក៏ត្រូវតែស្របតាមបទបញ្ជាដែលចែងក្នុងច្បាប់របស់ម្ចាស់ផ្ទះ។

រូបឡូហ្គូអាវមិនចាត់ទុកជា សារ/រូបផ្សព្វផ្សាយទេ។

## ជំពូកទី ៤៖ ប្រតិបត្តិការទូទៅ

**<u>មាត្រាទី ១៨៖</u>**

កាលបរិច្ឆេទនិងពេលវេលានៃការចាប់ឆ្នោតក្នុងវគ្គជម្រោះនឹងសម្រេចដោយគណៈកម្មាធិការប្រតិបត្តិក្នុងពេលជុំនំដែលប្រព្រឹត្តិទៅជារាងរាល់ឆ្នាំនៅប្រទេសបារាំងនារដូវស្លឹកឈើលាស់។ការចាប់ឆ្នោតនេះអាចនឹងប្រព្រឹត្តិឡើងបន្ទាប់ពីការបើកកម្មវិធីប្រកួតក្នុងពេលដែលមានវត្តមាននៃមហាជនយ៉ាងច្រើន ឬធ្វើនៅពេលវេលាកំណត់ណាមួយ។ អាចធ្វើបាននៅពេលមុនប្រកួត។

ក្រុមប្រកួតដែលបានឡើងមកដល់វគ្គ១ភាគ៤នៃការប្រកួតក្នុងឆ្នាំកន្លងមកមិនអាចជួបគ្នាបានក្នុងជុំទី១ឡើយ។ក្នុងករណីដែលអាក់ខានមិនបានចូលរួមពីក្រុមណាមួយគេនឹងយកមកជំនួសនូវក្រុមដែលឈ្នះឬក្រុមលេខ២របស់ពានរង្វាន់ជាតិជាតិ(Coupe de nation)

ក្នុងវគ្គជម្រុះគេអនុញ្ញាតឲ្យតែ២៤ក្រុមឡើងបន្តរទៅទៀតក្នុងវិញ្ញាសារ៣ទល់៣បុរស ចំណែកឯវិញ្ញាសារដ៏ទៃទៀតបានតែ១៦ក្រុមទេ។ទង្វើទាំងនេះត្រូវធ្វើឲ្យសមស្របតាមនិតិវិធីដែលសម្រេចដោយគណៈកម្មាធិការប្រតិបត្តិ(FIPJP)ក្នុងពេលប្រជុំនារដូវស្លឹកឈើលាស់។

ការប្រកួតបន្តក្នុងជុំបញ្ចប់ត្រូវសម្រេចដោយការចាប់ឆ្នោតដោយសំអាងទៅលើលទ្ធផលនិងពិន្ទុតាមនិតិវិធីដែលបានសម្រេចទុកជាមុនរបស់គណៈកម្មាធិការប្រតិបត្តិ។ ការចាប់ឆ្នោតអ្វីផ្សេងទៀតមិនអនុញ្ញាតឲ្យឡើយ។

ក្រុមដែលបដិសេធចូលរួមក្នុងការប្រកួតនឹងត្រូវបានជម្រុះចេញជាស្វ័យប្រវត្តិពីជុំបន្តបន្ទាប់ហើយពិន្ទុដែលក្រុមនេះទទួលបានពីជុំកន្លងមកទុកជាមោឃៈ។ក្នុងករណីដែលក្រុមឬកីឡាករមិនបានវត្តមានគេត្រូវបញ្ជូនបញ្ហានេះទៅគណៈកម្មាការវិនិច្ឆ័យនៃការប្រកួតសម្រេច។

<u>ចំណាំ៖</u> បច្ចុប្បន្ននេះ របៀបរបបនៃការអនុវត្តវគ្គជម្រុះ៥ទៅ៦ជុំគឺធ្វើតាមប្រព័ន្ធស្វីស។ បន្ទាប់ពីវគ្គនេះមកគេចែកជាក្រុមប្រកួតដោយមាន៣ក្រុមក្នុង១បណ្តាញ(Group)។សារុបទៅបានជា៨ក្រុម។ក្រុមដែលជាប់ជាលំដាប់ថ្នាក់លេខ១ដល់លេខ៨ក្នុងវគ្គជម្រុះមិនបាច់ប្រកួតវគ្គទី១ទេក្នុងការប្រកួតជាបណ្តាញ(group)ដោយចាំជួបអ្នកឈ្នះក្នុងការប្រជែងគ្នានៃ២ក្រុមទៀត។ក្រុមដែលឈ្នះនៅជុំទី២នេះនឹងឡើងទៅវគ្គ១ភាគ៤។

ខាងស្ត្រីនិងយុវជនវិញបន្ទាប់ពីជាប់វគ្គជម្រុះនៃប្រពន្ធ័ស្វិសត្រូវចូលលេងបន្តរក្នុងវគ្គ១ភាគ៨ដែលជាវគ្គជម្រោះបញ្ចប់(ចាញ់ចេញឈ្នះបន្តរទៅវគ្គ១ភាគ៤។

ក្រុមដែលចាញ់ក្នុងបណ្តាញ(group)ទាំង៨ក្រុមព្រមទាំង៤ក្រុមដែលចាញ់នៅវគ្គ១ភាគ៤អាចនឹងចូលប្រកួតក្នុងវគ្គ១ភាគ៤នៃពានរង្វាន់ជាតិ(Coupe de nation)។

**<u>មាត្រាទី ១៩៖</u>**

វគ្គនិមួយៗនៃជើងឯកពិភពលោកត្រូវយកពិន្ទុឲ្យបាន១៣ពិន្ទុទើបឈ្នះ។លើកលែងតែការប្រកួតដែលកម្រិតពេលវេលាសំរាប់បុរស៧៥នាទីនិង៦០នាទីសម្រាប់ផ្នែកពីរទៀត។ បើសិនជាការប្រកួតណាមួយមិនបានបញ្ចប់ដល់១៣ពិន្ទុគេអាចបន្ថែមពេលវេលា។

**<u>មាត្រាទី ២០៖</u>**

ក្រុមដែលដែលធ្លាក់ក្នុងការប្រកួតក្នុងរច្ចនាសំព័ន្ធស្វិស,ក្រុមដែលធ្លាក់ក្នុងការប្រកួតក្នុងវគ្គបណ្តាញ(Group)៣ក្រុមក្នុង១បណ្តាញសំរាប់បុរសអាចចូលរួមប្រកួតយកពានរង្វាន់ជាតិ «The Nations Cup»។ ការប្រកួតនេះអាចប្រកួតជាក្រុម(group) ឬ ប្រកួតជាជម្រុះអាស្រ័យតាមពេលវេលាឬតាមចំនួនទីលានប្រកួតដែលផ្តល់ឲ្យ។ចំពោះយុវជនឬស្ត្រី,ក្រុមដែលចាញ់ក្នុងវគ្គ១ភាគ៤អាចចូលមកប្រកួតវិញបានក្នុងវគ្គដដែល។

ការប្រកួតពានរង្វាន់ជាតិ(coupe de nation)អាចផ្តល់ឲ្យក្រុមជាប់លេខ១និងលេខ២ចូលប្រកួតជើងឯកពិភពលោកក្នុងអាណត្តិក្រោយដោយមិនបាច់ប្រកួតវគ្គទី១ក្នុងការប្រកួតបន្ទាប់ពីឈ្នះការប្រកួតរច្ចនាសំព័ន្ធស្វិសបើសិនជាក្រុមអ្នកឈ្នះជាប់លេខ១ដល់លេខ៨មិនបានចូលប្រកួត។

**<u>មាត្រាទី ២១៖</u>**

វគ្គជម្រុះដូចជាការរើសយកលំដាប់ថ្នាក់លេខ៥ដល់លេខ៨មានសារៈសំខាន់ចំពោះចំណាត់ថ្នាក់របស់សហព័ន្ធនិមួយៗក្នុងចំណោមសហព័ន្ធទាំងអស់។ក្នុងភាពដូចគ្នានេះដែរគេអាចរើសយកវិធីជម្រុះនោះទៅប្រើការដូចជាក្នុងការប្រកួតតាមតំបន់ ឬអ្វីផ្សេងៗទៀតដែលសម្រេចដោយFIPJPគណៈកម្មាធិការប្រតិបត្តិ។

**មាត្រាទី ២២៖**

កីឡាករ/ក្រុមដែលឈ្នះនិងចាញ់នៅវគ្គផ្តាច់ព្រ័ត្រនឹងត្រូវប្រកាសជ័យលាភីជាជើងឯកពិភពលោកចំពោះអ្នកឈ្នះភ្ជាប់ជាមួយនូវមេដាយមាស។ឯអ្នកចាញ់វិញប្រកាសជ័យលាភីជាជើងឯករងពិភពលោកភ្ជាប់ជាមួយនូវមេដាយប្រាក់។

កីឡាករ/ក្រុមពីរដែលបានមកដល់វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនឹងទទួលបានមេដាយសំរិទ្ធ។

តំណាងសហព័ន្ធ FIPJP នឹងប្រគល់នូវសញ្ញាប័ត្រសំគាល់ដល់កីឡាករ និងសហព័ន្ធដែលកីឡាករឬក្រុមទាំងបួនតំណាងឲ្យ។ លើសពីនេះទៀតជើងឯកពិភពលោកនិងបំពាក់នៅអាវជើងឯកដែលមានពណ៌ឥន្ទធនូនិងទទួលពានរង្វាន់សម្រាប់ខ្លួននិងសំរាប់សហព័ន្ធដែលគេតំណាងឲ្យ។

ដូចបានសរសេរនៅក្នុងសៀវភៅ(cahier de charge) អ្នករៀបចំត្រូវចែកពានរង្វាន់ដល់ត្រឹមវគ្គ១ភាគ៤ ផ្តាច់ព្រ័ត្រក្នុងការប្រកួតជើងឯកពិភពលោក និង១ភាគ២ក្នុងការប្រកួតពានរង្វាន់ជាតិ (The Nations Cup) ថែមទាំងរង្វាន់ផ្សេងៗទៀតជាកាដូអនុស្សាវរីយ៍ដល់ អ្នកកីឡា, អ្នកតំណាង, អាជ្ញាកណ្តាល និងមន្ត្រីដែលបានចូលរួម។

**មាត្រាទី ២៣៖**

ចំពោះលំដាប់ថ្នាប់នៃវគ្គជម្រុះនៃកីឡាវាយស៊ីបជើងឯកពិភពលោកដែលមានក្បួនច្បាប់របស់គេផ្ទាល់ ក៏ត្រូវធ្វើស្របទៅតាមការសម្រេចក្នុងពេលចាប់ឆ្នោតនៃការប្រកួតជើងឯកពិភពលោកក្នុងវិញ្ញាសារក្រុម។

## ជំពូកទី ៥៖ តំណាងសហព័ន្ធ និងគណៈវិនិច្ឆ័យ

**មាត្រាទី ២៤៖**

នៅក្នុងការប្រកួតជើងឯកពិភពលោក សហព័ន្ធ FIPJP ត្រូវតំណាងដោយប្រធាន អគ្គលេខាធិការ ហេរញ្ញឹករបស់ខ្លួន ឬ អ្នកតំណាងដែលបានចាត់តាំងដោយគណៈកម្មាធិការប្រតិបត្តិ។

វេជ្ជបណ្ឌិតប្រចាំក្នុងសហព័ន្ធ FIPJP ក៏គប្បីមានវត្តមានដែរ។គាត់មានភារវគ្គកិច្ចក្នុងធ្វើតេស្តរកសារធាតុដែលគេហាមឃាត់ ព្រមទាំងសារធាតុស្រា។ នាយកបច្ចេកទេសអន្តរជាតិក៏គប្បីចូលរួមដែរ។

ការប្រឡងយកសញ្ញាបត្តិអាជ្ញាកណ្តាលអន្តរជាតិនឹងធ្វើទៅនៅក្នុងពេលប្រកួតជើងឯកពិភពលោកបុរស៣ទល់៣។ប្រធាននៃគណៈកម្មាការអាជ្ញាកណ្តាលដែលអមដោយអាជ្ញាកណ្តាលគ្រូ២នាក់ចូលរួមនិងកាត់ក្តីក្នុងវគ្គប្រឡងនេះ។

ស្របតាមបទបញ្ញាដែលមានចែងក្នុងcahier de charge, តម្លៃចាយវាយក្នុងការធ្វើដំណើរ នឹងត្រូវរ៉ាប់រងដោយសហព័ន្ធ FIPJP រីឯថ្លៃស្នាក់នៅជាបន្ទុករបស់អ្នករៀបចំកម្មវិធី។ ប័ណ្ណឬលិខិតចេញចូលត្រូវផ្តល់អោយពួកគាត់។

**មាត្រាទី ២៥៖**

នៅរាល់ការប្រកួតជើងឯកពិភពលោកគេតម្រូវឲ្យមានគណៈកម្មាការវិនិច្ឆ័យដែលមានសមាសភាពដូចតទៅ៖

- ប្រធាននៃសហព័ន្ធទាំងពីរដែលចាត់តាំងដោយគណៈកម្មាធិការប្រតិបត្តិ
- សមាជិកមួយរូបពីសហព័ន្ធរៀបចំកម្មវិធី (ក្រៅពីប្រធាន)
- សមាជិកពីររូបមកពីគណៈកម្មាធិការប្រតិបត្តិ (ក្រៅពីប្រធានសហព័ន្ធ FIPJP) ដែលមួយក្នុងចំណោមពីរនាក់នោះ គឺជាប្រធាន។
- ប្រធានឬប្រធានស្តីទីនៃអាជ្ញាកណ្តាល។

**មាត្រាទី ២៦៖**

នៅក្នុងករណីដែលមានជម្លោះមុនឬកំពុងតែប្រកួត,គណៈវិនិច្ឆ័យទទួលបន្ទុកដោះស្រាយបញ្ហា។បើសិនជាវិវាទនេះធ្លាក់ដល់កម្រិតដែលត្រូវដោះស្រាយដោយបោះឆ្នោត សន្លឹកឆ្នោតរបស់ប្រធានទុកជាឈ្នះបើសិនជាសន្លឹកឆ្នោតទាំងសងខាងស្មើគ្នា។

ការកោះហៅប្រជុំគណៈកម្មាការវិនិច្ឆ័យត្រូវសម្រេចដោយប្រធាន។ការប្រជុំនេះនឹងអាចធ្វើបានត្រូវមានវត្តមានរបស់សមាជិកយ៉ាងតិចបីនាក់។

ការកាត់ក្តីរបស់គណៈវិនិច្ឆ័យគឺជាសេចក្តីសម្រេចចុងក្រោយ។

## ជំពូកទី ៦៖ ពិធីការនៃកម្មវិធីប្រកួតជើងឯកពិភពលោក

**មាត្រាទី ២៧៖**

បទបញ្ជានិងលក្ខន្តិកៈនេះបានបញ្ចូលក្នុងcahier de charge នៃការប្រកួតជ្រើសរើសជើងឯកពិភពលោកដោយមានការគោរពពីម្ចាស់ផ្ទះដែលរៀបចំការប្រកួតក្នុងពេលហែរបង្ហាញនូវក្រុមប្រកួតឬក្នុងពេលបំពាក់មេដាយ។ក្នុងពេលចែករង្វាន់គេត្រូវជៀសវាងឲ្យអ្នកទស្សនាចូលក្នុងទីលាន។